## ពាក្យសម្រាប់គ្រើនកឋិនទី ១

ភន្តេ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន, វីអង្គកឋិនទាននេះជារបស់អស់លោកអ្នកពុទ្ធបរិស័ទសប្បុរសជនទាំងឡាយ.......................................ជាប្រធាន សុទ្ធសឹងតែពុទ្ធមាមកជន ប្រកបដោយបសាទសទ្ធានិងកុសលចេតនា ជាអសង្ហារិក ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យទាំង៣ បានបំពេញនូវបុញ្ញកិរិយាវត្ថុ ចេះលៃលកយកធនធានដែលគ្មានខ្លឹមសារ ធ្វើឱ្យជារបស់មានខ្លឹមសារកប់ទុកក្នុងព្រះពុទ្ធសាសនា ដើម្បីជាទ្រព្យមរតកសម្រាប់ប្រើប្រាស់ទៅក្នុងភពខាងមុខទៀត បានស្រុះស្រួលបបួលគ្នាផ្ដួចផ្ដើមបង្កើតជាអង្គកឋិនទាននេះឡើង ព្រមទាំងហែហមដ៏ជាឱឡារិកគគ្រឹកគគ្រេងតាមមាគ៌ា ដើម្បីនឹងយកមកវេរថ្វាយព្រះភិក្ខុសង្ឃ ដែលគង់ចាំវស្សាអស់ត្រៃមាសក្នុងទីវត្ត..................នេះ ហាក់ដូចសំពត់កោសេយ្យពស្ត្រអណ្ដែតត្រសែតពូដ៏អាកាសវេហានភាល័យ ហើយធ្លាក់ចុះមកក្នុងកណ្ដាលជំនុំសង្ឃជាសង្ឃទានស្មោះ, ឥតមានចំពោះព្រះករុណាអង្គណាមួយឡើយ ។

ហេតុនេះហើយ បើព្រះករុណាអង្គណាមានត្រៃចីវរទុព្វលភាពដាច់ដាច មិនអាចនឹងប្រើប្រាស់បាន ហើយចេះនូវអានិសង្ឃ ៥, នូវមាតិកា ៨, បលិពោធ២, អនត្ថតាការ:២៤, អត្ថតាការ:១៧ អាចញ៉ាំងសង្ឃឱ្យគ្រេកអរដោយកឋិនត្ថារកិច្ចបាន ក៏សូមមានព្រះពុទ្ធដីកាឆ្លើយមកចុះ, ព្រះសង្ឃនឹងអបលោកន៏ សំពត់កឋិននេះ ដល់ព្រះករុណាអង្គនោះ ដោយញត្តិទុតិយកម្មវាចាក្រាលគ្រងតទៅ ។

(*ភិក្ខុទី១ ប្រកាសសង្ឃចប់ហើយត្រូវឈប់បង្អង់ ២-៣ នាទីសិន សឹមភិក្ខុទី២ប្រកាសសង្ឃតទៅទៀត*) ។

## ពាក្យសម្រាប់គ្រើនកឋិនទី ២

ភន្តេ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន, ខ្ញុំព្រះករុណាជាអ្នកតំណាងព្រះសង្ឃគ្រប់អង្គក្នុងឱកាសនេះ, សូមពិត្រព្រះពុទ្ធដីកាចំពោះព្រះសង្ឃគ្រប់អង្គ សូមទានជ្រាប ។

យើងខ្ញុំទាំងអស់សុទ្ធតែមានត្រៃចីវរល្មមគ្រប់គ្រាន់ប្រើប្រាស់ហើយ, ប៉ុន្តែតាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញតែព្រះ.......................ទើបសមគួរនឹងក្រាលគ្រងនូវសំពត់កឋិននេះ ដោយលោកជាអ្នកចេះនូវអានិសង្ឃ ៥, ចាំនូវមាតិកា ៨, បលិពោត ២, អនត្ថតាការ: ២៤, អត្ថតាការ: ១៧ ហើយឆ្លៀវឆ្លាតក្នុងកឋិនការកិច្ច អាចញ៉ាំងសង្ឃឱ្យគ្រេកអរបាន ។

ហេតុនេះហើយ បើព្រះសង្ឃគ្រប់អង្គយល់ឃើញថា សមគួរដូចជាបកាសនវាចា ដែលខ្ញុំព្រះករុណាបានថ្លែងមកនេះ ក៏សូមបញ្ចេញនូវសទ្ទសញ្ញាថា **សាធុ** ឱ្យព្រមៗគ្រប់ព្រះអង្គទៅហោង ។

បាលីសម្រាប់សូត្រក្រាលកឋិន

**សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនចីវរំ(ទុស្សំ, វត្ថំ) ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ, សង្ឃោ ឥមំ កឋិនចីវរំ(ទុស្សំ, វត្ថំ)[២] ឥត្ថន្នាមស្ស[១](ជោតញ្ញាណស្ស) ភិក្ខុនោ ទទេយ្យ, កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។**

**សុណាតុ មេ ភន្តេ សង្ឃោ, ឥទំ សង្ឃស្ស កឋិនចីវរំ(ទុស្សំ, វត្ថំ) ឧប្បន្នំ។ សង្ឃោ ឥមំ កឋិនចីវរំ(ទុស្សំ, វត្ថំ) ជោតញ្ញាណស្ស ភិក្ខុនោ ទេតិ, កឋិនំ អត្ថរិតុំ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនវត្ថស្សស្ស ជោតញ្ញាណស្ស ភិក្ខុនោ ទានំ, កឋិនំ អត្ថរិតុំ, សោតុណ្ហស្ស  យស្ស នក្ខមតិ សោ ភាសេយ្យ។ ទិន្នំ ឥទំ សង្ឃេន កឋិនចីវរំ(ទុស្សំ, វត្ថំ) ជោតញ្ញាណស្ស ភិក្ខុនោ កឋិនំ អត្ថរិតុំ។ ខមតិ សង្ឃស្ស, តស្មា តុណ្ហី, ឯវមេតំ ធារយាមិ ។**

សូត្រអនុមោទនាកឋិន : **អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទនាហិ ។**

---

១.បាលីថា ឥត្ថន្នាមស្ស នេះត្រូវផ្លាស់ដាក់តាមនាមរបស់ភិក្ខុអ្នកក្រាលឱ្យរាល់បទ

១. សូត្រជ្រើសរើសយកមួយណាក៏បាន ទៅតាមសំពត់ដែលញាតិញោមប្រគេនជា ចីវរំ ទុស្សំ ឬ វត្ថំ